ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រឿងក្តីព្រហ្មទណ្ឌ
លេខៈ១២២
ចុះថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០០៨
សាលក្រមព្រហ្មទណ្ឌ
លេខៈ២៣(ឃ)
ចុះថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០០៩

តាងនាមប្រជារាស្ត្រខ្មែរ
តុលាការខេត្តបាត់ដំបង

បើកសវនាការជាសាធារណៈ នៅនាទីតុលាការខេត្តបាត់ដំបង នៅបន្ទប់ជំនុំជម្រះទី.....

កាលបរិច្ឆេទបើកសវនាការនៅថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០០៩

កាលបរិច្ឆេទប្រកាសសាលក្រមៈនៅថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០០៩

**ប្រធានក្រុមប្រឹក្សាជំនុំជម្រះ**

១-លោក .... ជាប្រធានក្រុមប្រឹក្សា
២-លោក .... ចៅក្រមប្រឹក្សា
៣-លោក .... ចៅក្រមប្រឹក្សា

**តំណាងអយ្យការ**

លោក .... ព្រះរាជអាជ្ញារង

**ក្រឡាបញ្ជីសវនាការ**

លោក ................

ជំនុំជម្រះរឿងក្តីព្រហ្មទណ្ឌលេខ ១២២ ចុះថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០០៨ ដែលមានជនជាប់ចោទ

១-ឈ្មោះ.....ភេទប្រុស អាយុ២១ ឆ្នាំជាតិខ្មែរ មានទីលំនៅកន្លែងកំណើតនៅភូមិទួលតាឯក ឃុំទួលតាឯក ស្រុកបាត់ដំបង ខេត្តបាត់ដំបង មានទីលំនៅសព្វថ្ងៃនៅភូមិទួលតាឯក ឃុំទួលតាឯក ស្រុកបាត់ដំបង ខេត្តបាត់ដំបង មានមុខរបរកម្មករសំណង់ មានកម្រិតវប្បធម៌ថ្នាក់ទី៤ ថ្មី កាន់សាសនាព្រះពុទ្ធ នៅលីវ មានឪពុកឈ្មោះ....ម្តាយឈ្មោះ.......ទោសពីមុនគ្មាន ដោយមានលោកមេធាវី..........ជាអ្នកការពារ។

ចិរវេលានៃការចាប់ឃុំខ្លួន......ថ្ងៃចាប់ពីថ្ងៃទី.........ខែ......ឆ្នាំ.......ដល់ថ្ងៃទី.......ខែ......ឆ្នាំ.......នៅពន្ធនាគារខេត្តបាត់ដំបង។

កាលបរិច្ឆេទនៃការឃុំខ្លួនបណ្តោះអាសន្ន ចាប់ពីថ្ងៃទី១១ ខែកុម្ភៈឆ្នាំ២០០៨ នៅពន្ធនាគារខេត្តបាត់ដំបង។

២-ឈ្មោះ..........ភេទប្រុស អាយុ២៩ ឆ្នាំសញ្ជាតិខ្មែរ កើតនៅភូមិទួលតាឯក ឃុំស្វាយប៉ោ១ ទីរួមខេត្តបាត់ដំបង ទីលំនៅសព្វថ្ងៃភូមិអូរតាគាំ២ ឃុំទួលតាឯក ស្រុកបាត់ដំបង ខេត្តបាត់ដំបង មានមុខរបរកម្មករ កម្រិតវប្បធម៌..........កាន់សាសនាព្រះពុទ្ធ នៅលីវ មានឪពុកឈ្មោះ...ម្តាយឈ្មោះ... ទោសពីមុន.....ដោយមានលោក...ជាអ្នកការពារ។

៣-ឈ្មោះ.........ភេទប្រុសអាយុ៣១ ឆ្នាំជាតិខ្មែរ កើតនៅភូមិ ទួលតាឯក ឃុំស្វាយប៉ោ១ ទីរួមខេត្តបាត់ដំបង មានទីលំនៅសព្វថ្ងៃ ភូមិអូរតាគាំ២ ឃុំទួលតាឯក ស្រុកបាត់ដំបង ខេត្តបាត់ដំបង មានមុខរបរ មិនពិតប្រាកដ កម្រិតវប្បធម៌....កាន់សាសនាព្រះពុទ្ធនៅលីវ មានឪពុកឈ្មោះ....ម្តាយឈ្មោះ...ទោសពីមុន...ដោយមានលោក...ជាមេធាវីការពារ។

៤-ឈ្មោះ..........ភេទប្រុស អាយុ១៨ឆ្នាំជាតិខ្មែរ កើតនៅភូមិ កំពង់ក្របី ឃុំឯកភាព ទីរួមខេត្តបាត់ដំបង ទីលំនៅសព្វថ្ងៃ ភូមិទួលតាឯក ឃុំទួលតា

ឯក ស្រុកបាត់ដំបង ខេត្តបាត់ដំបង របររកស៊ី មិនពិតប្រាកដ កម្រិតវប្បធម៌ ..........កាន់សាសនាព្រះពុទ្ធ នៅលីវ មានឳពុកឈ្មោះ.......ម្តាយឈ្មោះ..... ទោសពីមុន........ដោយមានលោក.......ជាមេធាវីការពារ។

ពីបទៈ ឃាតកម្មគិតទុកជាមុនប្រព្រឹត្តនៅភូមិទួលតាឯក ឃុំទួលតាឯក ស្រុកបាត់ដំបងខេត្តបាត់ដំបងកាលពីថ្ងៃទី ០៦ ខែកុម្ភៈឆ្នាំ២០០៨ តាមបញ្ញត្តិ មាត្រា៣ នៃច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ។

តាមដីកាបញ្ជូនរឿងឱ្យជំនុំជម្រះលេខ៣៦៦៨ ពសព្រទ ចុះថ្ងៃទី០៣ ខែតុលាឆ្នាំ២០០៨របស់ចៅក្រមស៊ើបសួរ ។

## ដើមបណ្តឹងរដ្ឋប្បវេណី

-ឈ្មោះ......ភេទប្រុសអាយុ៥៤ ឆ្នាំ ជាតិខ្មែរ មានទីលំនៅភូមិព្រៃទទឹង ឃុំជ្រៃ ស្រុកថ្មគោល ខេត្តបាត់ដំបង។

ក្នុងរឿងនេះខ្លួនមិនប្តឹងទាមទារសំណងអ្វីទេ គ្រាន់តែសុំឱ្យតុលាការផ្តន្ទាទោសជនល្មើសទៅតាមច្បាប់។

## ការប្រព្រឹត្តរបស់ជនជាប់ចោទ

កាលពីថ្ងៃទី០៦ ខែកុម្ភៈឆ្នាំ២០០៨ វេលាម៉ោង១០យប់ ជនល្មើស ឈ្មោះ......ភេទប្រុសដែលមានទីលំនៅភូមិទួលតាឯក ឃុំទួលតាឯក ស្រុកបាត់ដំបង ខេត្តបាត់ដំបង និងបក្សពួក បាននាំគ្នាពួនស្ទាក់ចាំកាក់ម៉ូតូ របស់ជនរងគ្រោះ ពេលឃើញម៉ូតូ របស់ជនរងគ្រោះជិះកាត់ស្របតាមផ្លូវរថភ្លើងមកខាងត្បូងបានចម្ងាយប្រមាណជា១០០ម៉ែត្រ ជនល្មើសរូបនេះ បានចេញមកកាត់ពីមុខម៉ូតូ ហើយបញ្ជាឱ្យឈប់ បន្ទាប់មកទៀតបក្សពួករបស់ជនល្មើស បានលូកហោប៉ៅរបស់ជនរងគ្រោះ ឈ្មោះ...........យកប្រាក់អស់ចំនួន១០០០០រៀល ចំណែកជនរងគ្រោះឈ្មោះ.......បានរត់ចេញពីម៉ូតូ ចម្ងាយប្រហែល ប្រាំម៉ែត្រ

តែត្រូវជនល្មើសស្ទាក់ជាប់ ហើយទាមទារយកទូរស័ព្ទដៃ ដោយជនរងគ្រោះមិនព្រមឱ្យ ជនល្មើសក៏កាប់និងចាក់ ទៅលើជនរងគ្រោះបណ្តាលឱ្យស្លាប់នៅនឹងកន្លែងតែម្តងបន្ទាប់ពីធ្វើសកម្មភាពទៅលើជនរងគ្រោះហើយ ជនល្មើសក៏នាំគ្នា រត់គេចខ្លួនអស់ទៅ។

## នាពេលសវនាការ

-តាមចម្លើយរបស់ជនត្រូវចោទឈ្មោះ.........បានឆ្លើយថា៖ ខ្លួនមិនបានសម្លាប់គេទេ ហើយក៏មិនបានដឹងថាគេស្លាប់ដែរ លុះព្រឹកឡើងទើបដឹង នៅថ្ងៃនោះម៉ោង៤ខ្លួននៅផ្ទះលុះដល់ម៉ោង៥ខ្លួនបានទៅលេងបាល់រួចមុជទឹក ហើយទៅមើលគេលេងបៀរ ឈ្មោះ............មកលេងផ្ទះខ្លួន ហើយខ្លួនក៏បបួលវាទៅបត់ជើងរួចទៅដើរលេង ឈរក្រោមដើមទឹកដោះគោម៉ោង១០ជាងទើបមកវិញខ្លួនមិនបានដឹងថាឈ្មោះ........ស្លាប់នៅពេលណាទេ លុះព្រឹកឡើងទើបដឹង តែមិនដឹងអ្នកណាសម្លាប់ទេ តែនៅយប់នោះវេលាម៉ោង១២ឈ្មោះ......រកខ្លួនរួចប្រាប់ខ្លួនថា វាកាប់គេ ខ្លួនក៏បានស្តីឱ្យវា ហើយវាក៏ចេញបាត់ ទៅ ខ្លួនមិនធ្លាប់ស្គាល់ឈ្មោះ..........ឈ្មោះ........ផ្ទះរបស់ខ្លួនតែម្នាក់ឯងនៅម៉ោង១២យប់នោះពុំឃើញមានកាន់កាំបិតទេ ឈ្មោះ........ខ្លួនស្គាល់ ព្រោះនៅភូមិជាមួយ តែយប់នោះខ្លួនមិនបានជួបទេ ខ្លួនមិនធ្លាប់មានដាវសាម៉ូរ៉ៃទេ ។ ខ្លួនបានឈរលេងនៅក្រោមដើមទឹកដោះគោ ចាប់ពីម៉ោង៨យប់រហូតដល់ម៉ោង១០យប់ ដោយមានគ្នាបីនាក់មានឈ្មោះ.........

-តាមចម្លើយរបស់ឈ្មោះ......ដែលជាសាក្សីបានឆ្លើយថាៈថ្ងៃកើតហេតុខ្លួនមិនដឹងច្បាស់ថាម៉ោងប៉ុន្មានទេ ព្រោះពុំមានម៉ោងមើល តែឮគេនិយាយថាម៉ោងប្រហែល១០ នៅយប់នោះខ្លួនពីរនាក់ជនរងគ្រោះថានៅផ្សារបឹងឈូកដោយជនរងគ្រោះឈ្មោះ..........ឌុបដល់តារាងបាល់ជិតផ្លូវរថភ្លើង ស្រាប់តែ

ឃើញមនុស្សបីនាក់មកកាក់ម៉ូតូហើយលូកហោប៉ៅជនរងគ្រោះ រួចជនរងគ្រោះក៏ដើរទៅមុខម៉ូតូខ្លួនបានចុះមកក្រោយ ដើរស្របតាមតាមផ្លូវរថភ្លើង ពីរនាក់កៀកខ្លួនជាប់ដោយម្នាក់កាន់កាំបិត ម្នាក់ទៀតមិនដឹងកាន់អ្វីទេ ហើយម្នាក់ទៀតតាមឈ្មោះ........រួចឈ្មោះ.....ស្រែកថា អាជាចាំអញហៅគ្នាឱ្យមក ជួយរួចអាម្នាក់កាន់កាំបិត កាប់ខ្លួនមួយកាំបិត រួចរត់តម្រង់ទៅរកឈ្មោះ..........ខ្លួនក៏រត់គេច ក្នុងចំណោមគ្នាវានោះមានពីរនាក់មិនពាក់អាវទេ ដោយយកអាវមកចងចង្កេះម្នាក់ទៀតមិនដឹងថាពាក់ឬអត់ទេ។ អ្នកដែលកាន់កាំបិត ខ្លួនមិនចាំមុខមាត់ទេ តែពួកគេមានរាងដូចឈ្មោះ....នេះដែរ ខ្លួនមិនបានឃើញគេកាប់ឈ្មោះ..........ផ្ទាល់ទេព្រោះខ្លួនរត់ទៅហៅគ្នាមកជួយ ចម្ងាយពីកន្លែងកើតហេតុទៅកន្លែងដែលគ្នារបស់ខ្លួនច្រៀងខារ៉ាអូខេ មានចម្ងាយ៣០០ម៉ែត្រទៅ៤០០ម៉ែត្រ ខ្លួនបានរត់ប្រហែលជាង១០នាទី ត្រឡប់មកវិញ ក៏ឃើញឈ្មោះ.....របួសក្រលៀន ម្រាមដៃ និងក្បាលដោយស្នាមចាក់ យប់នោះពួកវាលូកយកប្រាក់របស់ខ្លួនអស់១០០០០រៀល និងទូរស័ព្ទរបស់ឈ្មោះ........ចំណែកប្រាក់របស់ឈ្មោះ......សល់ប៉ុន្មាននោះ ខ្លួនមិនដឹងទេ។

-តាមការអានចម្លើយរបស់សាក្សីឈ្មោះ..........

## សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ

មានភស្តុតាង និងពិរុទ្ធភាពគ្រប់គ្រាន់លើឈ្មោះ.........ភេទប្រុសអាយុ២១ឆ្នាំ(មានសាវតា)ឈ្មោះ........ភេទប្រុស អាយុ២៩ឆ្នាំ(មានសាវតា)ឈ្មោះ.......ភេទប្រុសអាយុ៣១ឆ្នាំ(មានសាវតា) និងឈ្មោះ.........ភេទប្រុសអាយុ១៨ឆ្នាំ(មានសាវតា) ពីបទឃាតកម្មគិតទុកជាមុន ប្រព្រឹត្តនៅភូមិ ទួលតាឯក ឃុំទួលតាឯក ស្រុកបាត់ដំបង ខេត្តបាត់ដំបង កាលពីថ្ងៃទី០៦ ខែកុម្ភៈឆ្នាំ២០០៨ តាមបញ្ញត្តិមាត្រា៣នៃច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ ហេតុដូច្នេះសម្រេច

ប្តឹងសុំលោកចៅក្រមជំនុំជម្រះផ្តន្ទាទោស ជនជាប់ចោទខាងលើទៅតាមបញ្ញត្តិច្បាប់។

## សេចក្តីសន្និដ្ឋានរបស់មេធាវីការពារជនជាប់ចោទ

ថ្ងៃកើតហេតុទី០៦ ខែកុម្ភៈឆ្នាំ២០០៨ តាមចម្លើយជនជាប់ចោទរូបនេះ បានឆ្លើយបដិសេធថា គេមិនបានចូលរួម ប្រព្រឹត្តបទល្មើសទេ ដោយហេតុថា ម៉ោង៥ទៅមើលគេលេងបាល់ រួចមកមើលវីដេអូហើយនៅម៉ោង៨យប់ ទៅលេងដូចចម្លើយសាក្សី **ទសភ** បញ្ជាក់ ថ្ងៃនោះមេឃងងឹត ទាំងជនជាប់ចោទនិងសាក្សីឆ្លើយថាមេឃងងឹតមិនអាចមើលគ្នាស្គាល់ទេ ចម្លើយសាក្សីដាក់បន្ទុក និងដោះបន្ទុកមិនអាចឆ្លើយដាក់បន្ទុកលើជនជាប់ចោទទេ ព្រោះមេឃងងឹត។

តាមមាត្រា៣៩១ក្រមនីតិវិធីព្រហ្មទណ្ឌថ្មីមាត្រា៣៥០ ការប្រកាសពីពិរុទ្ធភាព ស្នើសុំលោកចៅក្រមលើកលែងចោទជនជាប់ចោទរូបនេះ តាមមាត្រា៣៩១,៣៥០ និង៣០៧ ក្រមនីតិវិធីព្រហ្មទណ្ឌថ្មី។

-តាមសម្តីចុងក្រោយរបស់ជនជាប់ចោទឈ្មោះ......សំណូមពរ សុំលើកលែងចោទប្រកាន់។

-ក្រោយពីបានស្តាប់ចម្លើយរបស់ជនត្រូវចោទ

-ក្រោយពីបានស្តាប់ចម្លើយរបស់ដើមបណ្តឹង

-ក្រោយពីបានស្តាប់ចម្លើយរបស់សាក្សី

-ក្រោយពីបានពិនិត្យភស្តុតាង

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារជនត្រូវចោទ

-ក្រោយពីបានស្តាប់សម្តីចុងក្រោយរបស់ជនត្រូវចោទ

-ក្រោយពិនិត្យពិចារណាត្រឹមត្រូវតាមច្បាប់

## តុលាការខេត្តបាត់ដំបង

## យល់ឃើញថា៖

-ចម្លើយរបស់ឈ្មោះ.........ឃើញបញ្ញាកាន់ដាវសាម៉ូរ៉ៃស្របនិងចម្លើយសាក្សីឈ្មោះ........អ្នកកាន់អាវុធដាវសាម៉ូរ៉ៃ នោះមានរូបរាងប្រហាក់ប្រហែលនឹងឈ្មោះ.......ស្របនឹងចម្លើយសាក្សីឈ្មោះ........ដែលបានឃើញឈ្មោះ........ឈ្មោះ.... និងម្នាក់ទៀត កំពុងឈរកាក់ម៉ូតូចម្ងាយ៣០ម៉ែត្រ ពីកន្លែងកើតហេតុស្របពេលដែលជនជាប់ចោទទាំងបួននាក់រត់គេចខ្លួន ក្រោយពីពេលកើតហេតុរួច អាចកំណត់បានថា អំពើសម្លាប់ជនរងគ្រោះនោះពិតជាអំពើរបស់ឈ្មោះ...

-ជនជាប់ចោទត្រៀមដាវសាម៉ូរ៉ៃ បង្ហាញពីការគ្រោងទុករបស់ជនជាប់ចោទ។

-មានពិរុទ្ធភាពលើជនជាប់ចោទ ទាំងបួននាក់ពីបទសម្លាប់មនុស្សគិតទុកជាមុន តាមមាត្រា៣ នៃច្បាប់ស្តីពីស្ថាន ទម្ងន់ទោសនៃបទឧក្រិដ្ឋប្រព្រឹត្តនៅភូមិទួលតាឯក ឃុំទួលតាឯក ស្រុកបាត់ដំបង ខេត្តបាត់ដំបង កាលពីថ្ងៃទី០៦ ខែកុម្ភៈ ឆ្នាំ២០០៨។

-ដើមបណ្តឹងរដ្ឋប្បវេណី មិនប្តឹងទាមទារសំណងជំងឺចិត្ត ប៉ុន្តែសុំឱ្យតុលាការផ្តន្ទាទោសជនល្មើសទៅតាមច្បាប់ ។

## ហេតុដូច្នេះ

## សម្រេច

១-ផ្តន្ទាទោសៈ

ក-ឈ្មោះ.......ភេទប្រុសអាយុ២១ឆ្នាំ ជាតិខ្មែរ ដាក់ពន្ធនាគារកំណត់ ១៥ឆ្នាំ (ដប់ប្រាំឆ្នាំ) តម្រូវឱ្យធ្វើការងារ ដោយគិតចាប់ពីថ្ងៃចាប់ខ្លួន ថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០០៨

ខ-ឈ្មោះ.........ភេទប្រុសអាយុ២៩ឆ្នាំ ជាតិខ្មែរ

គ-ឈ្មោះ.........ភេទប្រុសអាយុ៣១ឆ្នាំ ជាតិខ្មែរ

ឃ-ឈ្មោះ.........ភេទប្រុសអាយុ១៨ឆ្នាំ ជាតិខ្មែរ

ដាក់ពន្ធនាគារតម្រូវឱ្យធ្វើការងារក្នុងម្នាក់ៗ១៥ឆ្នាំ (ដប់ប្រាំឆ្នាំគត់) គិតចាប់ពីថ្ងៃចាប់ខ្លួនបាន **ពីបទ** មនុស្សឃាតគិតទុកជាមុនប្រព្រឹត្តនៅភូមិទួលតាឯក ឃុំទួលតាឯក ស្រុកបាត់ដំបង ខេត្តបាត់ដំបងកាលពីថ្ងៃទី០៦ខែកុម្ភៈឆ្នាំ២០០៨ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៣នៃច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ។

២-សាលក្រមនេះជំនុំជម្រះ និងប្រកាសជាសាធារណៈចំពោះមុខជនជាប់ចោទឈ្មោះ...និងដើមបណ្តឹងរដ្ឋប្បវេណី កំបាំងមុខជនជាប់ចោទឈ្មោះ.....ទុកសិទ្ធិប្តឹងទាស់និងឧទ្ធរណ៍តាមកំណត់ច្បាប់។